តើអ្នកជឿលើរឿងអបិយជំនឿ មន្តអាគម ខ្មោចព្រាយបិសាចដែរឬទេ? បើជឿ តើជឿកម្រិតណាដែរ? ពេលនេះ ខ្ញុំមានរឿងរ៉ាវរបស់ រដ្ឋ ចាន់បុល មកចែករំលែក។

---

វាជាអារម្មណ៍ ដ៏អាថ៌កំបាំងរបស់ខ្ញុំដែលបានកើតឡើងរយៈពេលពីរបីថ្ងៃកន្លងមកហើយមុនពេលយើងរើមកនៅផ្ទះចាស់កេរលោកយាយខ្ញុំនៅខេត្តកំពង់ធំ។

ខ្ញុំជាជាងមាស ការរើទីកន្លែងមិនសំខាន់ពេកទេព្រោះនៅទីណាក៏ខ្ញុំប្រកបរបររកស៊ីបានដែរ។

ម្លិះជា ភរិយារបស់ខ្ញុំ យើងទើបតែ រៀបការបានជាងមួយខែប៉ុណ្ណោះទេ។ ខ្ញុំរើមកនៅទីនេះព្រោះនាងត្រូវប្តូរការងារ ប្រាក់ខែខ្ពស់ហើយមានអនាគតល្អ ដូច្នេះ ផ្ទះកេរ៍លោកយាយដែលខ្ញុំជួលអោយគេពេលនេះត្រូវជួសជុលមកស្នាក់នៅខ្លួនឯងម្តង។

តាំងពីមកមើលទីតាំងនេះ ដំបូងភរិយាខ្ញុំចេះតែមានអារម្មណ៍មិនសូវល្អរួចមកហើយ ....

«បងបុល បងឯងមើលចុះផ្ទះលោកយាយដល់ទៅបួនឡូ គាត់ចែកអោយគេនៅក្បែរៗគ្នាទាំងអស់ ខុសអីតែផ្ទះយើង នៅដាច់ឆ្ងាយពីគេហើយ ក្បែរដីទំនេរនោះទៀត!បងឯងមើលចុះដីនោះដូចម៉េចមិនដឹងទេ!»

កាលពីសង្គមចាស់ បើតាមការតំណាលរបស់លោកឳពុកខ្ញុំ លោកយាយជាកូនសេដ្ឋីធំ មានទ្រព្យ ដីធ្លី វាលស្រែច្រើនហិច តា លេចវាលចូលព្រៃ លោកយាយចុះ ចោលគ្រួសារមកតាមលោកតាដែលជាអ្នកគ្មានធនធាន ដើម្បីគេចពីមង្គលការជាមួយនាយទាហានម្នាក់។

ក្រោយមកពេលលោកយាយទួយនិងតាទួតចូលជរាក៏បញ្ជាអោយអ្នកជាបាវព្រាវតាមស្វះស្វែងរកលោកយាយលោកតាហើយចែកទ្រព្យជាផ្ទះបួនខ្នងនេះអោយរក្សាគ្រប់គ្រងបន្ត។

ឳពុករបស់ខ្ញុំកូនប្រុសទីបួន តែធ្វើជាជាមន្ត្រីទ័ពជើងទឹកត្រូវចេញទៅនៅឆ្ងាយពីឳពុកម្តាយរហូតគឺចល័តចុះឡើង ចុងក្រោយ មរតកនេះត្រូវបានចែកចាយទៅជីដូនមួយខ្ញុំម្នាក់មួយឡូ ចំណែកផ្ទះចុងក្រោយនេះ ជាផ្ទះលើដីតែមួយដែលត្រូវបានមកខ្ញុំជាកូនទោលរបស់ឳពុកម្តាយខ្ញុំ។

ផ្ទះទីបួននេះនៅលើដីជាមួយពួកបងប្អូនជីដូនមួយខ្ញុំដែរគ្រាន់តែ វាហាក់ ឆ្ងាយពីគេបន្តិច ដោយរបាំងកូនព្រៃកតូចមួយ។

តែខ្ញុំពេញចិត្តវាព្រោះវាមានបរិវេណធំ សឹងតែអាចថា ពីរដងនៃផ្ទះបីមុនៗគ្រាន់តែវាចាស់បន្តិចដោយសារជា ស្ថាបត្យកម្មសម័យពីសង្គម ហើយវាមានបន្ទប់ច្រើនដូចជាវិមានតូចមួយដែរ ។

«បងឯងមិនព្រមស្តាប់ខ្ញុំសោះ!យើងជួលអោយគេយកលុយវិញទៅ ផ្ទះធំណាស់ហើយចាស់ទៀត!»

ប្រពន្ធខ្ញុំចេះតែរអ៊ូព្រោះនាងមិនចង់រស់នៅទីនេះ តែខ្ញុំយល់ឃើញខុសពីនាង។

ការទទួលកេរមតរក៍មិនមែនមានន័យថាយើងប្រើវាសម្រាប់រកលុយទេ តែវាត្រូវតែរស់នៅជិតស្និទ្ធ ថែទាំគ្រប់គ្រង ទើបសមជាការគោរពនិងផ្សារភ្ជាប់សេចក្តីរំលឹកអោយជិតស្និទ្ធជាមួយអតីតកាលនៃបុព្វបុរសគ្រួសារយើង។

ខ្ញុំជាមនុស្សមិនចេះភ័យខ្លាចហើយមិនជឿរឿងខ្មោចព្រាយអ្វីទាំងអស់ ទោះបីជាជីដូនមួយខ្ញុំនាំគ្នាបន្លាចលេងថា «ផ្ទះបុលឯងធំអញ្ចឹង តែពីរនាក់ប្តីប្រពន្ធហ៊ាននៅដែរ?!»

«បើពុំនោះទេយើងជួលជាន់ខាងក្រោមអោយគេហើយយើងនៅលើក៏បានដែរ!បើបងព្រមខ្ញុំហៅ អ្នកកូកជេរផ្ទះអោយពួកអង្គការ អោយគេមកមើល!»

ម្លិះតែងតែចង់អោយ មានអ្នកផ្សេងទៀតមកនៅក្បែរៗយើងតែខ្ញុំមិនមាត់មិនករថាព្រមរឺមិនចំពោះសំណូមពរនាងទេ គ្រាន់តែពន្យល់នាងថា «យើងជួសជុលវាអោយត្រឹមត្រូវសិនចាំគិតទៀត!»

ផ្ទះទីបីដែលឆ្ងាយពីខ្ញុំប្រហែល ជា៣០ម៉ែត្ររំលងព្រែកមួយនោះគឺកម្មសិទ្ធិបងស្រីជីដូនមួយជាកូនអ៊ុំស្រីខ្ញុំ ។

បងនោះឈ្មោះបឿន គាត់មេម៉ាយមានកូនស្រីពីរនាក់តែគាត់មានកូនប្រសារហើយមានចៅច្រើនសន្ធឹក។ ផ្ទះគាត់មិនស្ងាត់ទេ ។

ហើយផ្ទះពីរទៀតនោះគឺនៅជាប់ជញ្ជាំងគ្នាតែម្តង។ ពួកគេមិនសូវមើលទៅសន្លឹមដូចផ្ទះខ្ញុំនេះឡើយ។

បងបឿនធ្លាប់បបួលខ្ញុំដូរគ្នាព្រោះគាត់ចង់បានផ្ទះធំនេះតែខ្ញុំមិនព្រម។ លុះលឺពួកគាត់សួររឿងខ្លាចខ្ញុំចេះតែខឹងហើយកើតចិត្តចង់ជំនះថាខ្ញុំអាចរស់នៅលើផ្ទះកេរ៍នេះបាន។

នៅចំហៀងផ្ទះ មានកូនដីទំនេរមួយ ព័ទ្ធរបងចោលតែបែរជាមានច្រកតូចមួយចូលមកក្នុងដីខ្ញុំបាន។

ប្លង់ នៃផ្ទះនោះមើលទៅចម្លែកបន្តិចព្រោះបន្ទប់ទទួលភ្ញៀវជាន់ក្រោមធំពេក ឯបន្ទប់គេងមានជាច្រើនបន្ទប់តែតូចៗធំតែជាងគ្រែបន្តិប៉ុណ្ណោះ។

ផ្ទះបាយនៅខាងក្រោយ ដាច់ពីផ្ទះប្រមាណ១០ម។

ភរិយាខ្ញុំរអ៊ូច្រើនហើយនាងចង់ធ្វើកន្លែងធ្វើម្ហូបថ្មី គឺក្នុងផ្ទះតែម្តង។

«សម័យណោះហើយធ្វើផ្ទះបាយឆ្ងាយពេក ចុះនឹកឃ្លានយប់ព្រលប់ត្រូវដើរទៅរីយ៉ាងម៉េច?! អ្វីយ បុរាណណាស់»

ខ្ញុំធុញនាងពេក ក៏ព្រមអោយនាងធ្វើកន្លែងដាំស្លទំនើបមួយក្នុងបរិវេណបន្ទប់ទទួលភ្ញៀវដ៏ធំនោះ។

បងប្រុសជីដូនមួយខ្ញុំនៅផ្ទះទីមួយឈ្មោះបងសៅ។

ថ្ងៃរើផ្ទះចូល គាត់មកជួយរើដែរ ហើយបងសៅបានជាវព្រះពុទ្ធរូបសំរិទ្ធមួយអង្គមកអោយខ្ញុំគោរពបូជា។

ខ្ញុំទទួលមកហើយនៅពេលលោកសូត្រមន្តបន្តិចបន្តួចជាកិច្ចឡើងផ្ទះថ្មីរួច រួចភរិយាខ្ញុំក៏ទទួលព្រះសំរិទ្ធទៅទុកលើធ្នើសម្រាប់បូជា នាងដាក់ថ្វាយទៀនធូបដោយស្មោះស។

បន្ទប់ដេករបស់ខ្ញុំនៅចុងប៉ូចគេ នាជាន់ទីមួយគឺឡើងពីជណ្តើរត្រូវដើរឆ្លងបន្ទប់បីទៀតសិន។ ខ្ញុំរើសយកទីនោះព្រោះមានបង្អួចច្រើនហើយវានៅចុងផ្ទះផងងាយអោយខ្យល់បក់ចេញចូលស្រួលជាងគេ។

ខ្ញុំហៅជាងមកធ្វើចម្រឹងពីក្នុងដើម្បីអាចចំហរបង្អួចគេងយកខ្យល់អាកាសបាន។

ទីបំផុតដោយសារបន្ទប់សល់ច្រើនខ្ញុំទទួលកូនជាងពីរនាក់ ជាអ្នកស្រុក ប្រាសាទបល្ល័ង្គមកស្នាក់នៅជាមួយដោយអោយរស់នៅជាន់ខាងក្រោមហើយមិនយកកម្រៃអ្វីឡើយ ថ្នូរនឹងការជួយការងារផ្ទះជម្រះស្មៅ បោសជ្រះ ព្រោះផ្ទះធំត្រូវការកម្លាំងច្រើន។

ប្តីប្រពន្ធខ្ញុំគេងនៅលើគ្រែបេងធំមួយជាគ្រែកេរ៍របស់លោកយាយ។

គ្រែនោះធំណាស់ គឺប្រហែលជាទទឹងនឹងបណ្តោយ២ម៉ែត្រគុណនិង២ម៉ែត្រកន្លះ សម័យណោះគ្មានជាងណាគេធ្វើគ្រែធំយ៉ាងនេះទេ ហើយតម្លៃក៏មិនតិចពាន់ដុល្លារដែរ ចំណែកទម្ងន់គឺធ្ងន់ណែនលើកមិនចេញតែម្តង។

ពេលប្រពន្ធខ្ញុំលើកពូកដាក់រៀបចំ គឺនៅសល់ក្តារខាងៗទៀត ព្រោះពូកតូចជាងគ្រែ។

យប់ដំបូងដែលយើងរើចូលនៅ ក៏មានបងប្អូនពីភ្នំពេញមកលេងផឹកស៊ីអឹងកងដេកពេញផ្ទះ។ យប់នោះមិនឃើញមានអ្វីប្លែកដែរ គឺមានតែបរិយាកាសរហើយរំភើយ គេងលក់ស្រួលគ្រប់ៗគ្នា។

ដល់ថ្ងៃទី៣ ដែលបងប្អូនលាទៅវិញអស់សល់តែកូនជាងទាំងពីរនិងពូម្នាក់ខាងរបស់ភរិយាខ្ញុំ គាត់នៅបន្តរង់ចាំ ទិញតុឈើយកទៅភ្នំពេញ គាត់សម្រាន្តនៅជាន់ទី មួយដែរ តែមិនចូលបន្ទប់ទេគឺសម្រាន្តនៅរាលតែម្តង។

កណ្តាលយប់ខ្ញុំលឺសូរគាត់ក្រោកឡើងស្រែកឡូឡាហើយដាស់ហៅ កូនជាងខ្ញុំទាំងពីរឡើងមកជជែកគ្នារអ៊ុះៗ។

ខ្ញុំងងុយពេកក៏ ដេកបន្តចំណែកភរិយាខ្ញុំ គេចេញមកជជែកជាមួយពូកគេ។

ស្អែកឡើងពូគេ រួសរាន់ ចាកចេញទាំងព្រលឹមទៅភ្នំពេញវិញទាំងមិនទាន់បានទិញតុទេ។

ពេលបបរព្រឹកជាមួយគ្នាភរិយាខ្ញុំ បង្ហើបប្រាប់ថា ពូគេត្រូវខ្មោចលងហើយភ័យតក់ស្លុតចុះទៅដេកក្បែរពួកកូនជាងទាំងយប់។

ខ្ញុំមិនមាត់តែបង្ហាញទឹកមុខមិនសប្បាយចិត្តព្រោះគិតថាពូកគេនេះប្រឌិតរឿងរញ៉េរញ៉ៃលើផ្ទះ ជាកេរ្តិ៍លោកយាយខ្ញុំ។

ឃើញខ្ញុំដូចជាខឹង ម្ល៉ិះមិនហ៊ានបន្តនិយាយអ្វីច្រើនទៀតទេ តែខ្ញុំសម្គាល់ថា ភរិយាខ្ញុំហាក់ខ្លាចៗផ្ទះថ្មីរបស់យើង។

ព្រឹកព្រហាមនោះ ខ្ញុំមិនបានចេញទៅផ្សារទេដោយសារបបួលកូនជាងទៅជួសជុលបង្អួចមួយចំនួន នឹងរើ សម្ភារៈដែលមិនប្រើទៅទុកនៅឃ្លាំងខាងក្រោយ(អតីតផ្ទះបាយដែលប្រពន្ធខ្ញុំរអ៊ូ ថានៅឆ្ងាយពេកនោះ)។

ពួកយើងធ្វើការរហូតដល់ថ្ងៃត្រង់មេឃស្រទំធ្លាក់ រលឹម ហើយចាប់ផ្តើមភ្លៀងរិចៗដូចចង់កក់ខែ។ ឯប្រពន្ធខ្ញុំ ចេះតែស្រែកហៅអោយទៅផ្ទះខាងមុខវិញហូបបាយសិនខ្ញុំ នៅបន្តថា ចាំរួចរាល់តែម្តងសឹមហូបបាយសម្រាក។

«តោះ! ម៉ោ! ហូបបាយសិនៗ»

នាងហៅដដែលៗ។

កំពុងរើអីវ៉ាន់បង្ហើយក្នុងឃ្លាំងស្រាប់តែលឺសូរសម្រែកប្រពន្ធខ្ញុំស្រែកវ៉ាសយ៉ាងខ្លាំង។ ពួកយើងទាំងបីរបូតកេសអីវ៉ាន់ពីដៃហើយស្រលាំងកាំង។

ខ្ញុំស្រែកសួរទៅភ្លាម៖

«កើតស្អីក៏ស្រែកលឺម្លេះ!»

នាងមិនឆ្លើយមកទៀតសោះ ពួកយើងក៏ដើរទៅក្នុងផ្ទះរកមើល។

តែនៅចង្រ្កានបាយយើងរកនាងមិនឃើញទេ  យើងហៅផងរត់រកផងក៏ឃើញភរិយាខ្ញុំដេកសន្លប់បាត់ស្មារតី ស្ប៉ាបម្នាក់ឯងលើផ្ទះជាន់ទីមួយ។

នាឡិកាប៉ោលនៅពីលើក្បាល នាងចង្អុលម៉ោង១២ថ្ងៃត្រង់។

មេឃខាងក្រៅរលឹម គ្មានពន្លឺព្រះអាទិត្យច្បាស់ទេ ហើយទិដ្ឋភាពជុំវិញផ្ទះស្ងាត់ជ្រងំ។

នាងប្រហែលភ័យពេកបានជាស្រែកហៅខ្ញុំអោយមកហូបបាយច្រើនដងមិនឃើញមកនាងក៏ដួលសន្លប់?

ខ្ញុំបន្លំចិត្តខ្លួនឯងបែបនេះនៅតែមិនបានស្រណុក  ព្រោះវាមិនសមសោះ។ ប្រពន្ធខ្ញុំមិនដែលមានបញ្ហាសន្លប់អីទេពីមុនមក។

ស្នូរជើងរត់មកដល់មាត់ហៅសួរល្វើយៗគឺបងបឿនកូនស្រីគាត់និងកូនប្រសារគាត់។

សម្រែកម្លិះច្បាស់ជាលឺដល់ទីនោះ។

«ប្រពន្ធឯងកើតអីហ្នឹង?!»

បងបឿនសួរហើយគាត់ភ័យសស្លើតលើកគ្រានាងកោសរឹតអោយដឹងខ្លួន។

ខ្ញុំត្រៀមដឹកនាងទៅពេទ្យដែរស្រាប់តែម្លិះរើហើយដឹងខ្លួនដោយស្រែកភ័យដដែលៗថា«បងៗៗៗ»

គឺនាងហៅខ្ញុំ។

ខ្ញុំស្ទុះទៅច្របាច់ដៃប្រពន្ធហើយសួរះ

«កើតអីអ្ហះអូន?!»

«ខ្មោចលង!»

នាងនិយាយខ្លីប៉ុណ្ណេះទាំងហត់គយូសស្លេកបបូរមាត់។

ខ្ញុំខ្មាសក្មួយៗខ្ញុំនិងកូនជាងណាស់។ នាងចេញតែបង្កើតរឿងប្លែកៗក្នុងផ្ទះគង់តែមានថ្ងៃគេរត់ចេញ លែងនៅជាមួយអស់ទេ។

ក៏ងាកទៅបង្គាប់ពួកគេថា៖

«តោះ ទៅរៀបបាយទឹក គ្មានខ្មោចពីណាមកទេ!»

កូនជាងនាំគ្នាចុះទៅដី ឯបងបឿនខ្សឹបសួរម្លិះ៖

«ឯងឃើញអីនិយាយមកបងមក!»

ម្លិះស្រក់ទឹកភ្នែក ឯកូនបងបឿនកាន់ដៃប្ដីនាងជាប់មើលមុខគ្នាជាសម្ងាត់។

ខ្ញុំជ្រួញចិញ្ចើមចង់ស្រែកបន្ទាសថាប្រពន្ធខ្ញុំភ័យស្លើតស្លក់ជឿសម្ដីពូកគេពេកបានជាអញ្ចឹងប៉ុន្តែក្រឡេកទៅម្លិះឃើញប្រពន្ធស្លេកពេកខ្ញុំទប់ចិត្តនៅស្ងៀមវិញ។

ប្រពន្ធខ្ញុំប្រាប់ទៅបងជីដូនមួយខ្ញុំថា នាងបានឡើងមករកបិទបង្អួចខ្លាចភ្លៀងធំ ក៏លឺសំឡេងក្មេងស្រែកយំ យំលឺទៅៗយំមិនបាត់ សួរមិនឆ្លើយ រហូតដល់នាងត្រូវតាមរកនៅបន្ទប់នីមួយៗ។

ម្លិះឡើងមកនៅតែម្នាក់ឯងព្រោះអាងថានេះជាពេលថ្ងៃហើយប្ដីនិងកូនជាងនៅក្បែរៗផ្ទះមិនបានទៅផ្សារទេ។

នាងមកដល់មាត់ទ្វារបន្ទប់ទីមួយឃើញក្មេងតូចស្លៀកក្បិនម្នាក់អង្គុយជ្រប់មុខយំ។ ម្លិះចូលទៅជិតក្មេងនោះក៏ងើបមុខមក ដែលមុខនាងគ្មានច្រមុះនឹងភ្នែកទេធ្វើអោយនាងភ័យស្លុតស្មារតីដួលសន្លប់ឈឹង។

ខ្ញុំគិតថា វាជាការកុហក រឺជារឿងស្រមៃរបស់នាង។

តែខ្ញុំនៅបន្តស្ដាប់ ដោយងាកមុខចេញព្រោះបងបឿនដូចជាស្លុងស្ដាប់ណាស់ហើយប្រពន្ធខ្ញុំនិយាយបន្ត។

«បងបឿន! ពូខ្ញុំអញ្ចឹងដែរ យប់មិញម៉ោង ប្រហែល១ គាត់សម្រាន្តលក់ត្រង់នេះលក់ ស្រាប់តែមានគេដាស់គាត់ អង្រួនគាត់ហើយគាត់ភ្ញាក់មក អត់មានមនុស្សអីម្នាក់ទេ! គាត់បានឮនៅក្នុងបន្ទប់ទីមួយនេះសំឡេងស្រីៗជជែកគ្នាវាយកូនក្មេងយំ។ ផ្ទះយើងអត់ក្មេងទេ គាត់ភ័យក៏សំងំសូត្រធម៌ សំឡេងបាត់លឺបន្តិចក៏លឺដដែលមកទៀតហើយលឺដល់ទ្រាំធ្មេចមិនបាន។»

ខ្ញុំគំហក៖

«យើងជឿពូកយើងពេក គាត់ស្រវឹងហ្នឹង! ខំជឿទៅអញ្ចឹងបានមកដួលសន្លប់អត់ប្រយោជន៍!»

ខ្ញុំបន្ទោសម្លិះ តែបងបឿនលើកទឹកចិត្តអោយម្លិះនិយាយ នាងនិយាយបន្តភ្លាមៈ

«ព្រឹកមិញខ្ញុំលាងចានខាងក្រោមស្រាប់តែដាច់ទឹក មេឃក៏ងងឹតរកភ្លៀង ខ្ញុំរត់ឡើងមករកបិទបង្អួច ភ្លាមនោះកញ្ចក់ក្រោយខ្នងខ្ញុំជ្រុះធ្លាក់ វាមិនសមថាដោយសារខ្យល់ទេ! កញ្ចក់នោះម៉ឺងណាស់ មិនងាយធ្លាក់ទេ ប្ដីខ្ញុំចងវាឡើងជាប់!»

ខ្ញុំងាកទៅរកមើល កញ្ចក់នៅជាប់ម៉ឺងលើជញ្ជាំង.....

«មានធ្លាក់ឯណា?»បងបឿននិយាយតបនឹងម្លិះ។

នាងសម្លឹងទៅទីនោះហើយក៏ស្រលាំងកាំងហើយស្លេកស្លាំងជាងមុន ។

«វាបែកហើយ! កញ្ចក់នេះបែកច្បាស់ណាស់!»

ខ្ញុំដកដង្ហើមធំៈ

«ហ៊ឹមបងបឿន គិតម៉េចទៅបើម្នាក់ៗស្រមៃសាហាវអញ្ចឹង!!»

តាមពិតខ្ញុំចង់ដៀមដាមប្រពន្ធខ្ញុំថា ទាំងគេនិងពូគេ សុទ្ធតែពួកពូកែស្រមៃហើយមកទម្លាក់កំហុសលើខ្មោច។

«ខ្ញុំអត់ស្រមៃទេ អំបែងវាមុតជើងខ្ញុំ មើលទៅ!»

នាងលើកជើងមកក៏គ្មានអំបែងមុតអីនោះដែរ នាងភាន់ភាំងរលះរលាំងរកមើលតក់ស្លុតរញ៉ីរញ៉ូវតែខ្លួនឯង។

ខ្ញុំរអ៊ូៈ

«ខ្មោចមែនវាមិនអីទេ វាអីអាមនុស្សបន្លាចខ្លួនឯងនេះហើយ! តោះក្រោកមក បងគ្រាទៅក្រោមហូបបាយ»

នាងរលីងរលោងនិយាយដូចភ្ញាក់ៈ

«អុះម៉ោងប៉ុន្មានហើយ មិនទាន់ដាំបាយផង!»

ខ្ញុំញាក់ចិញ្ចើម នាងងើបមុខមើលម៉ោងហើយភ្លាត់មាត់ទៀតៈ

«អីគេហ្នឹងម៉ោង១២ហើយ?»

ខ្ញុំងឿងឆ្ងល់ហើយវិលវល់?

មុននេះក្រែងនាងស្រែកហៅពួកខ្ញុំម្ដងជាពីរដងអោយមកហូបបាយ?

«ចុះមិញក្រែងថាបាយឆ្អិន?!»

នាងងឿងឆ្ងល់ងាកមកមើលមុខខ្ញុំ។ ខ្ញុំបន្ថែម៖

«បងនៅក្រោយលឺអូនឯងស្រែកហៅក្មេងៗអោយមកហូបបាយ!»

នាងស្លើតស្លក់រលីងរលោង បែរមកអោបខ្ញុំហើយយំ៖

«ស្រែកអី? បាយអី? ខ្ញុំមិនទាន់ទិញម្ហូបទេ! រៀបថាដាំបាយដែរ ទើបតែបានលាងឆ្នាំងក៏ដាច់ទឹកហើយឡើងមកលើរកបិទទ្វារបង្អួច ក៏សន្លប់រហូតដល់ពេលនេះ!»

ខ្ញុំងើបមុខមើលបងស្រីខ្ញុំ ហើយពួកយើងទាំងបួននាក់នៅស្ងៀមដោយភាពពិភាល់។

«ប្រហែលភ្លៀង ប្ដីឯងស្ដាប់ច្រលំហើយ!»

បងបឿននិយាយកាត់សាញ តែអ្វីម្យ៉ាងសម្ងាត់លេចឡើងក្នុងកែវភ្នែកគាត់។

ពួកយើងចុះដល់ក្រោមឃើញកូនជាងកំពុងរៀបចំដាំបាយតែអត់ទឹកចេញមែន។

បងបឿនក៏និយាយកាត់៖

«តោះនាំគ្នាទៅដាំបាយផ្ទះបង! នៅទីនោះមានទឹក!»

បងបឿននិងកូនគាត់គ្រាអូនម្ស៉ិះទៅ។

កូនប្រសាគាត់សន្យាថាទៅកាប់មាន់ធ្វើម្ហូបហើយគេរត់ទៅមុន។

ខ្ញុំឆ្លៀតពេលងាកសួរនាំកូនជាងខ្ញុំ៖

«នែ៎មុនហ្នឹងពួកអ្អែងមានលឺម្ស៉ិះហៅយើងហូបបាយអត់អ្ហា?!»

ពួកគេមើលមុខគ្នាធ្វើងើមង៉ាមហើយឆ្លើយ៖

«អត់ផង!»

ខ្ញុំបុកពោះ?

មិញនេះនាងនិយាយអ្វីៗចម្លែកៗខ្ញុំចោទថានាងរវើរវាយស្រមើស្រមៃ។ ពេលនេះ ធ្លាក់ដល់ខ្ញុំខ្លួនឯងវិញ តើអ្នកណាស្រមៃអោយប្រាកដ?

មកដល់ផ្ទះបងប្អឿនខ្ញុំសំកុករង់ចាំ បាយទឹកតែចិត្តចាប់ផ្ដើមចម្លែក។ ម្តងម្កាលខ្ញុំដាច់ចិត្តសម្លឹងទៅផ្ទះខ្ញុំភ្លៀកៗ។

ទីនោះពិតជាធំហើយស្ងាត់។

ខ្ញុំគិតថា យកល្អខ្ញុំគួរសួរនាំពូខាងប្រពន្ធខ្ញុំសិន។

ព្រឹកមិញអន់ចិត្តដែលគាត់រត់មិនលាស្រួលបួល ទើបខ្ញុំមិនចង់និយាយរកតែពេលនេះមានរឿងចម្លែក ខ្ញុំត្រូវតែសួរនាំ។

«អាឡូពូ! ដល់ណាហើយ?!»

ពូខាងប្រពន្ធខ្ញុំកំពុងជិះ ឡានឈ្នួលដល់ខ្ញុំរៀបរាប់រឿងប្រពន្ធខ្ញុំនិងសំឡេងដែលហៅខ្ញុំហូបបាយគាត់ស្លុតតែម្តងហើយរៀបរាប់ប្រាប់ខ្ញុំវិញជាប់រដឹក។

«បុលអើយបុល បុលឯងកុំខឹងពូ ស្តាប់ហើយក្មួយពិចារណាមើលចុះ! យប់មិញក្តៅស្អុះពេកពូចេញមកដេកអានសៀវភៅក្រៅបន្ទប់ តែម្នាក់ឯង! ពួកកូនជាងឯងហៅពូមើលទូរទស្សន៍ពូអត់ចុះទេ ហើយក៏លក់មួយស្រលេតស្រាប់តែដូចមានអ្នកណាម្នាក់កាន់ប្រអប់ដែកមួយដែលមានកាក់ប្រាក់ពេញហើយមកឈរក្រឡុកចុះឡើងក្បែរក្បាលពូរហូតដល់ពូភ្ញាក់ក៏បាត់សូន្យមិនឃើញស្រមោលអ្នកណាសោះ! បន្ទាប់មកពូឮសំឡេងកាក់ផ្សេងទៀតនៅក្នុងបន្ទប់គប់លេងចុះឡើងឆឹងៗដូចមានក្មេងលេង ដូចមាននរណាម្នាក់មានសល់កាក់សេនច្រើនណាស់កាន់ទៅមករ៉ើករ៉ាក់ហើយបន្ទាប់មកមនុស្សស្រីឈ្លោះគ្នាល្វើយៗហើយក្មេងចាប់ផ្តើមយំ។ ពូក្រោកឡើងរៀបនឹងដើរទៅក្នុងបន្ទប់នោះមើលព្រោះលឺច្បាស់ពេក ស្រាប់តែមាននរណាម្នាក់ទាញបង្អួចក្រោយខ្នងរបស់ខ្ញុំ។ ខ្ញុំគិតថាវាជាចោរ ក៏រត់ទៅរុញមើលតែគ្មាននរណាម្នាក់នៅទីនោះសោះ! ពូរៀបតែចូលមកក្នុងហើយរត់ទៅដេកក្បែរពួកកូនជាង ស្រាប់តែក្រឡេកទៅឃើញពន្លឺពីរោងឡានបាយចាស់ មើលទៅដូចមានអ្នកណាបើកទូរទស្សន៍មើលនៅទីនោះ!»

ខ្ញុំភ្លាត់មាត់ខឹងមួម៉ៅ៖

«អីវ៉ាន់ទើបតែលើកទៅទីនោះហ្នឹង? មានទូរទស្សន៍ពីណាមក?!»

«ត្រូវហើយ! មានរឿងមួយចំនួនដែលបានកើតឡើងចម្លែកណាស់បុលអើយ! អស់ពីទូរទស្សន៍បើក ពូប្រុងចូលមកក្នុងផ្ទះលែងរវល់ស្រាប់តែលឺសូរគេងូតទឹកក្នុងបន្ទប់ទឹកជាន់ទីមួយ។ ក្រៅពីឯងនិងម្លិះមានអ្នកណាទៀត ហេតុអីមានគេងូតទឹក? ខ្ញុំហៀបស្រែកសួរ ពីរនាក់ឯងក្រែងចូលងូតទឹកចង់សួរថាថីបានងូតទឹកយប់ម្លេះ ស្រាប់តែកន្ទុយខ្ញុំឃើញមនុស្សចាស់ស្លៀកក្បិនជាច្រើននាក់ដើរកាត់ពីក្រោមផ្ទះ។ ពេលពូតក់ស្លុតហើយងាកទៅរកបង្អួចពូ ពួកគេងើយមើលមកពូ! ពូគាំងចលនាធ្វើអ្វីមិនកើតចិត្តមួយគិតថាកំពុងយល់សប្ដិព្រោះអ្នកស្លៀកក្បិនទាំងនោះ មិនមែនដើរទេគឺអណ្ដែតទៅកាន់ដីចាស់របងខាងក្រោយនោះហើយ ពូក៏ប្រមូលកម្លាំងស្រែកឡើងតែម្ដង ហើយប្រពន្ធឯងក៏ចេញមក! គ្រប់យ៉ាងក៏រលាយបាត់»

លឺការពណ៌នានោះហើយខ្ញុំចាប់ផ្ដើមលែងនឹកបាយទឹក។

បង្ខំចិត្តហូបជាមួយគេមួយម៉ាត់មួយក ឯម្លិះក៏និយាយរឿយៗ «បងបឿនខ្ញុំខ្លាចណាស់!»

បងស្រីខ្ញុំ គាត់និយាយលួងពួកខ្ញុំថា៖

«ចាំបងនិមន្តគ្រូសង្គ្រោជមកសូត្រអោយ! ចាំមើលបងទៅគេងនៅទីនោះកំដរពួកឯងប៉ុន្មានយប់រហូតដល់អ្វីៗរៀបរយសិន!»

ខ្ញុំដើរទៅក្រោយលាងដៃ ក៏ស្រាប់តែចៃដន្យលឺសំឡេងមនុស្សខ្សឹបគ្នា។ តាមពិតគឺកូនស្រីបងបឿននិងប្ដីរបស់គេ។

ខ្ញុំមិនចង់យកចិត្តទុកដាក់ទេតែត្រចៀកស្ដាប់លឺច្បាស់ៗថា៖

«អូនឯងឃើញអត់បងប្រាប់ហើយ ថាផ្ទះហ្នឹងមានខ្មោចនាហ្មឹន បងធ្លាប់ឃើញណា៎! អោយតែខែភ្លៀងបងឃើញតែញយ គឺដើរទៅដីដែលគេព័ទ្ធរបងចោលនោះ! ដល់ត្រឹមនោះក៏រលាយបាត់អស់ហ្មង»

ខ្ញុំភ្ញាក់ព្រើត....អញ្ចឹងសោះបានជាពួកគេតែងតែធ្វើមុខចម្លែកៗពេលទៅដល់ផ្ទះខ្ញុំ។ មុននេះប្រហែលម្លិះពិតជាភ័យបានជាស្រែកខ្លាំងក្នុងយល់សប្ដិហើយពួកគេលឺក៏នាំម្ដាយរត់ទៅ??

ខ្ញុំគ្មានចម្លើយទេ ហើយផ្ទៀងស្ដាប់បន្ត ប្រពន្ធនិយាយឡើងម្ដង៖

«អាណិតពូបុលនិងមីងណាស់! មិនដឹងធ្វើម៉េចទេ!»

ខ្ញុំបុកពោះ ហើយចាប់ផ្ដើមគិតនិងចេះកើតសង្ស័យពីរឿងអប្បិយជំនឿ។ ចេញមកវិញ ខ្ញុំអង្គុយលេងក្បែរបងបឿនហើយនិយាយលួងគាត់អោយសារភាពប្រាប់៖

«បងអ្នា! បងឯងដឹងរឿងស្អីខ្លះទាក់ទងនឹងផ្ទះរបស់ខ្ញុំ និយាយមកមើល៍បងឯងកុំលាក់ខ្ញុំណា!»

បងបឿនសម្លឹងខ្ញុំស្ងួត ហើយមាត់គាត់និយាយយឺតៗ ពេលចិត្តខ្ញុំកំពុងអន្ទះសា៖

«ហ៊ឹម! ឯងកុំឆាប់ភ័យពេក! វាគ្មានស្អីទេ! ផ្ទះយើងនៅតែជាផ្ទះរបស់យើង!»

«បងឯងដឹងរឿងអីខ្លះ?!»

«ធ្លាប់មានក្មេងៗដែលទៅឃ្វាលគោ វាឃើញថាផ្ទះនឹងមានខ្មោចស្លៀកក្បិន ដើរទាំងហ្វូងៗ វាទៅនិយាយប្រាប់អ្នកស្រុក! វាជារឿងតពីមាត់មួយទៅមាត់មួយទេ!»

ខ្ញុំជ្រួលច្រាល់ ម្លិះក៏សំណូមពរ៖

«យប់នេះ យើងគេងផ្ទះបងបឿនទៅ!»

«អត់ទេ! ដើរដេកផ្ទះគេអាម៉េចផ្ទះឯងមានសោះហ្នឹង?!»

ខ្ញុំប្រកែកភ្លាមៗមែនតែចិត្តខ្ញុំវែងព្រួយ។

កូនជាងលូកមាត់មកពីចម្ងាយ៖

«បើបងគាត់សម្រាន្តនៅឯណោះអោយគាត់សម្រាន្តសិនទៅ ផ្ទះនោះពួកខ្ញុំមើលថែអោយក៏បាន! ខ្ញុំគេងច្រើនយប់ហើយមិនដែលឃើញអីផង!»

កូនជាងទាំងពីរដូចជាមិនជឿរឿងអស់នេះទាល់តែសោះ។

ចំណែក ឯបងបឿននិយាយបន្ថែមពីក្រោយពួកគេ៖

«ផ្ទះរបស់យើងមិនអាចដើរចោលបានទេ! កាន់តែមិនទៅ កាន់តែមិនហ៊ានចូលនៅ! យប់នេះបងទៅដេកកំដរពួកឯងរហូតដល់ពួកឯងលែងខ្លាច!«

បងបឿនខ្ញុំ គាត់ជាស្រីមេម៉ាយប្តីស្លាប់តាំងពីកូននៅ៧ឆ្នាំ។ គាត់កាន់ធម៌អាថ៌ខ្ជាប់ មិនយកប្តីទៀត ហើយគាត់ជាមនុស្សល្អណាស់។ ខ្មែរយើង អោយតែបានមនុស្សបែបនេះជាគ្នា ក៏កក់ក្តៅរឿងខ្មោចព្រាយមួយអន្លើដែរ។ បានគាត់សន្យាអញ្ចឹង ខ្ញុំក៏រាងធូរចិត្ត។

ល្ងាចបន្តិច ខ្ញុំបបួលប្រពន្ធត្រឡប់ទៅផ្ទះមុន។

ម្លិះគេនៅរៀបចំដាំបាយទឹកខាងក្រោម ខ្ញុំឡើងមកលើជាន់ទីមួយម្នាក់ឯងត្រៀមកន្លែងអោយបងបឿនមកសម្រាន្ត។

ខ្ញុំចូលបន្ទប់ខ្ញុំរកមើលខ្នើយកន្ទេលស្រាប់តែពូកខ្ញុំសើមទទឹកអស់ ដោយសារភ្លៀងសាចហើយមិនបានបិទបង្អួច។

ខ្ញុំមួហ្មងណាស់លើកសារពូកយកទៅហាលហើយត្រឡប់មកសារកន្ទេលដែលក្រាលក្រោមពូកនោះចេញទៅ។

ពេលចាប់ផ្តើមជូតគ្រែអោយស្ងួតខ្ញុំប្រទះឃើញអក្សរពីរជួរតូចៗនៅគែមគ្រែខាងជញ្ជាំង។

វាដូចជារបៀនរឺគាថាអ្វីម្យ៉ាងដែលសរសេរជាសម្រាយ តែអានមិនដាច់ស្រួលទេ។

ទោះយ៉ាងនោះក៏ដោយ អក្សរនោះដូចជាគេឆ្លាក់ដៃហើយស្មើស្អាត មានក្បាច់ល្អណាស់ សមតែអ្នកណាម្នាក់ ជំនាន់ជីដូនជីតាខ្ញុំ អោយគេឆ្លាក់ទុកជាចេតនា?

ខ្ញុំចេញមករៀបចំបន្ទប់ខាងក្រៅ ថាក្រាលកន្ទេលគេង តម្រៀបគ្នាទាំងបីនាក់តែម្តងទៅព្រោះគ្រែក៏ទទឹក។

ទោះយ៉ាងណាពេលរៀបចំអ្វីៗខ្ញុំចេះតែមិនអស់ចិត្តនឹងអក្សរពីរជួរនោះ។

ទីបំផុតខ្ញុំបានយកទូរសព្ទមកថតវាទុក ថានឹងអាលបានជួបលោកនឹងទូលសួរ។